**លិខិតចំហជូនចំពោះ**
**សម្ដេចក្រឡាហោម ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**លោកជំទាវបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**
**ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ៖** សំណើសុំចំណាត់ការតាមផ្លូវច្បាប់ទៅលើករណីរបស់ **ឧកញ៉ា ហេង សៀ អតីតឧកញ៉ា ឌួង ឆាយ និង លោក អ៊ុក កុសល** អតីតស្នងការនគរបាលខេត្តកំពង់ធំ លើករណីអំពើហិង្សាក្នុងគ្រួសារ ការបៀតបៀន និងប្រើអំពើហិង្សាផ្លូវភេទលើស្ត្រី។

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ យើងខ្ញុំជាប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលកំពុង ធ្វើការដើម្បីលើកកម្ពស់សិទ្ធិមនុស្សរបស់ស្ត្រី និងសមភាពយេនឌ័រនៅកម្ពុជា ដូចមានរាយនាមខាងក្រោម មានការខកចិត្តជាខ្លាំងដែលស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធមិនបានអនុវត្តឱ្យបានជាក់លាក់ និងមានប្រសិទ្ធភាពតាមគោលការណ៍ច្បាប់ទៅលើករណីហិង្សា និងការបៀតបៀនផ្លូវភេទកន្លងមក។ នៅក្នុងករណីទាំងនេះ ជនរងគ្រោះមិនបានទទួលនូវយុត្តិធម៌ពេញលេញ ដែលជាហេតុបង្កឱ្យប៉ះពាល់យ៉ាងខ្លាំង ដល់ប្រសិទ្ធភាពនៃការអនុវត្តន៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងជំរុញឱ្យមានការកើនឡើងនូវអំពើហិង្សា និងការបៀតបៀនផ្លូវភេទ លើស្ត្រី និងក្មេងស្រីជាបន្តបន្ទាប់។ ចំណាត់ការកន្លងមកក្នុងការបញ្ឈប់តំណែង និងបន្ថយឋានន្តរសក្តិដែលជាចំណាត់ការរដ្ឋបាល ឬការស្ងាត់ស្ងៀមចំពោះមន្ត្រីដែលមានអំណាច គឺមិនទាន់ជាដំណោះស្រាយពិតប្រាកដ និងមិនបានផ្តល់នូវយុត្តិធម៌សម្រាប់ស្ត្រី និងក្មេងស្រីរងគ្រោះឡើយ ហើយការណ៍នេះបង្កបន្តវប្បធម៌និទណ្ឌភាពទៅវិញ។ ការប្រើអំពើហិង្សាក្នុងគ្រួសារ ការបៀតបៀនផ្លូវភេទ និងប៉ុនប៉ងរំលោភសេពសន្ថវៈ ជាបទល្មើសឧក្រិដ្ឋ ដែលជនល្មើសគួរតែត្រូវបានផ្តន្ទាទោសទៅតាមច្បាប់។ ជាការសង្វេគណាស់ទៅហើយ ដែលស្ត្រីរងគ្រោះត្រូវរស់នៅជាមួយនឹងអតីតកាលដ៏អាក្រក់នេះអស់មួយជីវិតរបស់គាត់ នៅពេលដែលស្ត្រីខំជម្នះនិយាយចេញមកនូវរូបភាព និងបទពិសោធន៍ដ៏ឈឺចាប់នេះ ក្នុងគោលបំណងតែមួយគត់គឺដើម្បីទទួលបានយុត្តិធម៌សម្រាប់ពួកគាត់។ ពេលនេះប្រជាពលរដ្ឋ បានសម្តែងចេញនូវការស្អប់ខ្ពើមចំពោះអំពើហិង្សាលើស្ត្រី និងកំពុងរង់ចាំតាមដានចំណាត់ការរបស់រាជរដ្ឋាភិបាល ជាពិសេសស្ថាប័នមានសមត្ថកិច្ចទៅលើករណីរបស់ ឧកញ៉ា ហេង សៀ ក៏ដូចជាករណី លោក ឌួងឆាយ និង លោក អ៊ុក កុសល ផងដែរ ខណៈករណីផ្សេងៗទៀតដែលមិនត្រូវទទួលបានការចាប់អារម្មណ៍ឬត្រូវបានដឹងឮ ដោយសារតែជនរងគ្រោះជាច្រើន មិនអាចទម្លាយនូវរឿងរ៉ាវ ដែលបានកើតឡើងចំពោះពួកគាត់ដោយសារកត្តាជាច្រើន រួមទាំងកត្តាសង្គមវប្បធម៌ផងដែរ។ ចំណាត់ការដ៏ត្រឹមត្រូវ និងយុត្តិធម៌របស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ នៅពេលនេះមានសារៈសំខាន់ណាស់ក្នុងការផ្ញើសារទៅស្ត្រីជាច្រើនទៀតដែលកំពុងរងគ្រោះឱ្យមានទំនុកចិត្ត និងជឿជាក់ឡើងវិញលើប្រព័ន្ធយុត្តិធម៌នៅកម្ពុជា និងជាសារទៅដល់សង្គម

ទាំងមូលថាកម្ពុជាពិតជាមិនអត់ឱនជាដាច់ខាតចំពោះអំពើហិង្សាលើស្ត្រី ហើយអ្នកប្រព្រឹត្តត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ដូចដែលរាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាទទួលស្គាល់លើលិខិតតូបករណ៍ និងវិធានការលុបបំបាត់ហិង្សាលើស្ត្រីនិងក្មេងស្រី ទាំងក្នុងច្បាប់ជាតិ និងអន្តរជាតិ។

នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការ នៃអង្គការសហប្រជាជាតិទទួលបន្ទុក លើអនុសញ្ញាស៊ីដ សម្រាប់ប្រទេសកម្ពុជា កាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០១៩ កន្លងទៅត្រង់កថាខណ្ឌ ១១(ង) និង កថាខណ្ឌ ៣៧(ឃ) បានចែងតម្រូវអោយរដ្ឋ *"ចាត់វិធានការជាក់ស្តែងដើម្បីពង្រឹងឯករាជ្យភាព និងភាពមិនលម្អៀងនៃប្រព័ន្ធយុត្តិធម៌ និងធានាថាករណីរើសអើងផ្អែកលើយេនឌ័រ និងអំពើហិង្សាលើស្ត្រី ត្រូវបានស៊ើបអង្កេតពេញលេញ ដោយជនល្មើសត្រូវបានកាត់ទោស និងទទួលទណ្ឌកម្ម ហើយជនរងគ្រោះទទួលបានដំណោះស្រាយគ្រប់គ្រាន់"* និង *"អនុម័ត និងអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តទូលំទូលាយ ដើម្បីទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ ដោយរួមបញ្ចូលទាំងការបៀតបៀនផ្លូវភេទ ព្រមទាំងបង្កើតនូវយន្តការទទួលបណ្តឹងឯករាជ្យមួយ ដើម្បីធានាថា ជនរងគ្រោះអាចទទួលបាននូវដំណោះ ស្រាយប្រកបដោយប្រសិទ្ធភាព និងធានាថា ជនល្មើសត្រូវបានផ្តន្ទាទោសចំពោះទង្វើរបស់ខ្លួន" ។*

ទន្ទឹមនឹងការធានាដល់យុត្តិធម៌ចំពោះជនរងគ្រោះ ជាការចាំបាច់បំផុតដែលអាជ្ញាធរពាក់ព័ន្ធក៏ត្រូវធានាដល់សុវត្ថិភាព សុខភាពផ្លូវកាយ និងផ្លូវចិត្តដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។ ការចូលរួមទាំងអស់គ្នាពីស្ថាប័នមានសមត្ថកិច្ច ព្រមទាំងសាធារណជនទាំងអស់ក្នុងការលុបបំបាត់នូវវប្បធម៌ស្តីបន្ទោសលើជនរងគ្រោះក៏ជាកត្តាសំខាន់ដែរ ព្រោះវាបានបង្កជាឧបសគ្គរាំងស្ទះដល់ការស្វះស្វែងរកយុត្តិធម៌ ព្រមទាំងធ្វើឱ្យស្ត្រីរងគ្រោះកាន់តែរងគ្រោះបន្ថែមទៀត។ ដល់ពេលវេលាដែលយើងត្រូវលុបបំបាត់វប្បធម៌និទណ្ឌភាព និងវប្បធម៌ស្តីបន្ទោសជនរងគ្រោះ ហើយត្រូវបង្កើនការគាំទ្រ និងគាំពារដល់ស្ត្រី និងក្មេងស្រីដើម្បីទទួលបាននូវយុត្តិធម៌សម្រាប់ពួកគាត់និងសង្គមជាតិផងដែរ។

អាស្រ័យហេតុនេះ យើងខ្ញុំទាំងអស់គ្នា សង្ឃឹមជឿជាក់ថា សម្តេចក្រឡាហោម លោកជំទាវបណ្ឌិតនិង ឯកឧត្តមនឹងអន្តរាគមន៍ លើករណីទាំងបីខាងលើប្រកបដោយប្រសិទ្ធភាពទៅតាមនីតិវិធីច្បាប់ ដើម្បីលើកស្ទួយស្ថានភាពប្រសើរឡើងនៃសិទ្ធិមនុស្សរបស់ស្ត្រីកម្ពុជា និងឈានទៅលុបបំបាត់រាល់ទម្រង់នៃការរើសអើង និងការប្រើអំពើហិង្សា គ្រប់រូបភាពលើស្ត្រីនិងក្មេងស្រី។

សូម សម្តេចក្រឡាហោម លោកជំទាវបណ្ឌិត និងឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃពុធ ៧រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១

**ស្ថាប័នសង្គមស៊ីវិលៈ**

១. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញា លុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW)

២. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

៣. យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)

៤. បណ្តាញ យេនឌ័រ និងអភិវឌ្ឍន៍កម្ពុជា (GADnet)

៥. អង្គការក្លាហាន (Klahaan)

៦. អង្គការ អាក់សិនអេតកម្ពុជា ( ActionAid Cambodia)

៧. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិនុស្ស លីកាដូ (LICADHO)

៨. អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍ (CHEC)

៩. សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

១០. គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ (និកហ្វិក)

១១. Cambodian Youth Network (CYN)

១២. អង្គការនារីដើម្បីសន្តិភាព (WPM)

១៣. សមាគមគាំពារស្ត្រីងាយរងគ្រោះ (ASVW)

១៤. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធ៌មនៅកម្ពុជា (ខុមហ្វ្រែល)

១៥. សម្ព័ន្ធសហជីពកម្ពុជា (CATU)

១៦. សហភាពការងារកម្ពុជា(CLC)

១៧.  អង្គការបន្ទាយស្រី (Banteay Srei)

១៨. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)

១៩. សមាគមអ្នកបម្រើការងារតាមផ្ទះ (ADW)

២០. សមាគមសម្ពន្ធ៍សហគមន៍កសិករកម្ពុជា (CCFC)

២១. អង្គការចំរើនស្ត្រី (WFP)

២២. Harpswell Foundation

២៣. អង្គការធនធានស្ត្រី (WRC)

២៤. អង្គការតម្លាភាពកម្ពុជា (TIC)

២៥. ក្តីស្រលាញ់គឺចម្រុះ (Love is Diversity)

**ខាងក្រោមនេះជាស្ថាប័នអង្គការសង្គមស៊ីវិល និងសហជីព ដែលបានគាំទ្របន្ទាប់ពីលិខិតចំហនេះបានចេញផ្សាយៈ**

២៦. សមាគមថែទាំសុខភាពគ្រួសារកម្ពុជា (RHAC)

២៧.មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
២៨. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍
២៩. អង្គការសីលការ (SILAKA)
៣០. បណ្តាញស្ត្រីអ្នកដឹកនាំវ័យក្មេង (YWLN)
៣១. សមាគមមណ្ឌលព័ត៌មានកម្មករ (WIC)
៣២. អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា (WNU)
៣៣. សមាគមតន្ត្រីយុវវ័យនាំសារ (MB)
៣៤. សកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍន៍ (SACD)
៣៥. ផ្តោតលើពិភពលោកខាងត្បូង/បាងកក (FGSB)
៣៦. ក្រុមសន្សំប្រាក់នារី (LSG)
៣៧. ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)

**ប្រជាពលរដ្ឋ៖**

1. អ្នកស្រី សុភា ម៉ូនីតា
2. អ្នកស្រី ខៀវ លក្ស្មី
3. Ms. Sophea Monita
4. Ms. Bou Chansokha
5. Ms. Chean Kosalvolak
6. Ms. Khim Khunnich
7. Mr. Ros Kuymeng
8. Mr. Dim Daradorn
9. Mr. Thach Ngounheng
10. Mr. Lor Chanveasna
11. Mr. Ven Saroeut
12. លោក ផាន់ ចាន់ហឿន
13. អ្នស្រី ហាយ នីតា
14. អ្នកស្រី ឃី សុភ័ណ្ឌ
15. Ms. Samnang Chanphavy
16. Ms. Oeun Samphors
17. Mr. Tren Channra
18. Ms. Hun Boramey
19. Ms. Soue Sambath
20. Ms. Soth Socheata
21. Ms. Phay Sary
22. Ms. Hong Nary
23. Ms. Tong SreyNich

24. Ms. Prum Sineath
25. អ្នកស្រី សែម ចិន្តា
26. អ្នកស្រី ថី ថានិត
27. អ្នកស្រី ម៉ៅ ចន្ទ័លក្ខិណា
28. អ្នកស្រី ធូ គីមធា
29. អ្នកស្រី ថៃ ឡៃអៀង
30. អ្នកស្រី គង់ ស្រីរត្ន័
31. អ្នកស្រី សឿង វិចារិកា
32. អ្នកស្រី ប៉ែន ស្រីប៉ុច
33. អ្នកស្រី បឿ សុភា
34. អ្នកស្រី មាស សំណាងវិសុទ្ធនា
35. អ្នកស្រី វ៉ាន ស្រីពេជ្រ
36. អ្នកស្រី ផន សុភីលាន
37. អ្នកស្រី មាស សំណាងកញ្ញនា
38. អ្នកស្រី ណុប តីម
39. អ្នកស្រី សំណាង ចាន់ផារី
40. អ្នកស្រី ពៅស្រីអូន
41. អ្នកស្រី ប្រាក់ ច័ន្ទភ័ស្តា
42. អ្នកស្រី ងន់ សៀវម៉ី
43. អ្នកស្រី ឆន រ៉ាដា
44. អ្នកស្រី រឿម ចាន់រ៉ា
45. Ms. Rina Chhun
46. Ms. Sreyden Hor
47. Ms. Em Sam Ath
48. Ms. Vong Chenda
49. អ្នកស្រី ជីន គឹមស្រៀង
50. អ្នកស្រី ឃឹម នីណា